**មាត្រា ១៩** : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង គ្រប់ក្រសួងស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ.ថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧*

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| **អ៊ុង ហ៊ួត** | **ហ៊ុន សែន** |

## អនុក្រឹត្យលេខ ៦០ អនក្រ.បក

## ស្តីពី

## ការបង្កើតស្នងការដ្ឋានពិសេសការពារបេតិកភណ្ឌ

~~~*~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
~~~

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត-០៨៩៧-១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀប និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស.រកម-០១៩៦-០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ០២៩៥ ១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពារតំបន់រមណីយដ្ឋាន និង រៀបចំតំបន់អង្គរហៅថាអាជ្ញាធរ អប្សរា

-បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

-បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៧

## សំរេច

**មាត្រា ១ :** បង្កើតស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌដែល មានទីតាំងក្នុងបរិវេណតំបន់អង្គរ នៃខេត្តសៀមរាប ។ ស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ ស្ថិតនៅក្រោមឱវាទផ្ទាល់របស់ ក្រសួងមហាផ្ទៃ ហើយមានភាតព្វកិច្ចសហការជាមួយអាជ្ញាធរអប្សរា និង អាជ្ញាធរខេត្តសៀមរាប ។

**មាត្រា ២ :** ស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ មានភារកិច្ច និងសិទ្ធិដូចតទៅ :-

**ក-ភារកិច្ច :**

១-លើកគំរោងផែនការ និង អនុវត្តវិធានការមុខជំនាញ តាមគោលការណ៍ដឹកនាំ ណែនាំ របស់ក្រសួងមហាផ្ទៃ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរៀប។

២-ការពារសុវត្ថិភាព សន្តិសុខ និង រក្សារបៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ក្នុងភូមិសាស្ត្រ តំបន់អង្គរ ដែលកំណត់ដោយអាជ្ញាធរអប្សរា ។

៣-ស្រាវជ្រាវ និង អនុវត្តវិធានការបង្ការទប់ស្កាត់ និង បង្ក្រាបរាល់អំពើល្មើសច្បាប់ ការបំផ្លិចបំផ្លាញ ការលួច លាក់ ប្លន់ ការទិញ លក់ ការដឹកជញ្ជូនបេតិកភ័ណ្ឌសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ ក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ។

៤-ការពារសុវត្ថិភាព សន្តិសុខភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ ដែលមកបំពេញបេសកកម្ម ធ្វើទស្សនកិច្ច ឬ ធ្វើទេសចរណ៍ក្នុងតំបន់អង្គរ ។

៥-ស៊ើបអង្កេតបទឧក្រិដ្ឋ ចាប់ខ្លួន ឃាត់ខ្លួន និង ត្រួតពិនិត្យ ឆែកឆេរ ជនល្មើសដែលពាក់ព័ន្ធក្នុងការបំផ្លិចបំផ្លាញ ការលួច លាក់ ប្លន់ ការទិញ លក់ ដឹកជញ្ជូនបេតិកភ័ណ្ឌ សម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ នៃ តំបន់អង្គរ កសាងសំណុំរឿង និងបញ្ជូនជនល្មើសជាមួយវត្ថុតាងទៅតុលាការ។

៦-បោះទីតាំងឈរជើងការពារ និង ចល័តយាមល្បាត ឃ្លាំមើលតាមចំណុចសំខាន់ៗ នៃតំបន់អង្គរ។

៧-សហការជាមួយស្នងការដ្ឋាន នគរបាលខេត្តសៀមរាប មេបញ្ជាការយោធភូមិភាគទី៤ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តសៀមរាប មេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប អភិរក្សដ្ឋានអង្គរ មន្ទីរធម្មការ និង កិច្ចការសាសនាខេត្ត មន្ទីរទេសចរណ៍ខេត្ត អង្គភាពគយរដ្ឋាករប្រចាំខេត្ត និង អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត ដើម្បីអនុវត្តវិធានការ បង្ការទប់ស្កាត់ បង្ក្រាបបទល្មើស និង ការបង្គ្រោះមហន្តរាយបំផ្លិចបំផ្លាញដល់បេតិកភ័ណ្ឌ វប្បធម៌ប្រវត្តិសាស្ត្រ ។

៨-តាមរយៈអាជ្ញាធរអប្សរា ធ្វើទំនាក់ទំនងជាមួយអង្គការ យូណេស្កូ និង អង្គការអន្តរជាតិនានា ដើម្បីទទួលការណែនាំ ផ្សព្វផ្សាយគោលការណ៍ផ្សេងៗ និង ទទួលជំនួយឧបត្ថម្ភបំរើអោយការងារ ការពារបេតិកភ័ណ្ឌវប្បធម៌ ។

៩-ធ្វើសេចក្តីរាយការណ៍ជាប្រចាំ ឬ ជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗ ដែលពាក់ព័ន្ធដល់ការអនុវត្តន៍ភារកិច្ច ក្នុងសមត្ថកិច្ចជំនាញរបស់ខ្លួនមកក្រសួងមហាផ្ទៃ និង អាជ្ញាធរអប្សរា និង ចម្លងជូនអាជ្ញាធរខេត្ត ។

១០-ធ្វើបញ្ជីគ្រប់គ្រងចលនទ្រព្យ និង អចលនទ្រព្យ របស់ស្នងការពិសេសការពារបេតិកភ័ណ្ឌ តាមការកំណត់របស់ក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

១១-ធ្វើការងាររដ្ឋបាល បុគ្គលិក ភស្តុភារ គណនេយ្យ និង ថវិកា តាមការកំណត់របស់ក្រសួងមហាផ្ទៃ និង អាជ្ញាធរអប្សរា ។

១២-អនុវត្តបទបញ្ជា និង ភារកិច្ចផ្សេងៗទៀត ដែលក្រសួងមហាផ្ទៃ និង អាជ្ញាធរអប្សរាប្រគល់អោយ។

**ខ-សិទ្ធិ :**

១-ទាមទារជាប្រចាំនូវបញ្ជីសារពើភ័ណ្ឌ បេតិកភ័ណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ពីអាជ្ញាធរអប្សរា ។

២-រៀបរៀងសំណើគោលការណ៍ជូនក្រសួងមហាផ្ទៃ និង/ឬ អាជ្ញាធរអប្សរា ដើម្បីចេញបទបញ្ជា និងចាត់វិធានការបង្ការ ទប់ស្កាត់បទល្មើស បង្គ្រោះថ្នាក់មហន្តរាយ បំផ្លិចបំផ្លាញ ព្រមទាំងស្នើអោយ មន្ទីរនានាជុំវិញខេត្ត ផ្តល់របាយការណ៍ពត៌មាន និងឯកសារពាក់ព័ន្ធដល់ការការពារបេតិកភ័ណ្ឌ សម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ ។

៣-គ្រប់គ្រងដឹកនាំ បញ្ជាកងកម្លាំងនគរបាលជាតិ ចំណុះស្នងការពិសេសការពារបេតិកភ័ណ្ឌ ដើម្បីធានាដល់ការអនុវត្តន៍គោលការណ៍បទបញ្ជា របស់ក្រសួងមហាផ្ទៃ និង អាជ្ញាធរអប្សរា ។

៤-អនុញ្ញាតច្បាប់សំរាក ដាក់ពិន្ទុ និងមូលវិចារ ស្នើសរសើរ ស្នើតែងតាំងមុខតំណែង បំពាក់ឋានន្តរសក្តិ ផ្ទេរភារកិច្ច ដាក់វិន័យ ដកហូតមុខតំណែង និង ឋានន្តរសក្តិនាយនគរបាល នាយនគរបាលរង និង ពលនគរបាលចំណុះស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ តាមការកំណត់ របស់ក្រសួងមហាផ្ទៃ ។

៥-អនុវត្តសិទ្ធិផ្សេងៗទៀត ដែលក្រសួងមហាផ្ទៃ និង អាជ្ញាធរអប្សរា ប្រគល់អោយ ។

មាត្រា ៣ : ស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ ថ្នាក់ស្មើស្នងការដ្ឋាននគរបាលខេត្ត ដឹកនាំដោយស្នងការមួយរូប និង មានស្នងការរង ជាជំនួយការ ។

មាត្រា ៤ : ការរៀបចំជាក់ស្តែង នូវភារកិច្ច សិទ្ធិ ទេនសម្ព័ន្ធ និង ក្របខ័ណ្ឌរបស់ស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ ត្រូវកំណត់ដោយប្រកាសក្រសួងមហាផ្ទៃ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប និង ប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ.ថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៩៧*

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| អ៊ឹង ហួត | ហ៊ុន សែន |

---

## II-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

## ប្រកាស

*រាជធានីភ្នំពេញ.ថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧*

## ប្រកាស លេខ ២៦៣ ព.ម.ប្រក

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*****